# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ ៤៤០ វណ.កក-៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោកប្រធានតុលាការខេត្ត កោះកុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីរបាយការណ៍ ចុះថ្ងៃទី២៥-០៦-៩៨ របស់លោក....ស្តីពីបណ្តឹងដិតចិត្តរបស់ឈ្មោះ....នាពេលសវនាការថ្ងៃទី២៣-០៦-៩៨ ។

ខ្ញុំសូមជម្រាបលោកប្រធានថា តាមរបាយការណ៍ដូចខាងលើ លោក.....ថា នាថ្ងៃទី២៣-០៦-៩៨ តុលាការខេត្តកោះកុង បានបើកសវនាការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីលេខ១៤ ចុះថ្ងៃទី០៥-០៣-៩៨ ដែលមាននាង...ជាដើមចោទ និងមានចុងចម្លើយ ៤ នាក់ ដែលមានកម្មវត្ថុបណ្តឹងសុំទាមទារគ្រប់គ្រងដីធ្លី ។

ពេលលោក......ប្រកាសបើកសវនាការតាមនីតិវិធី ដោយមានលោកព្រះរាជអាជ្ញាជាតំណាងអយ្យការមានយោបល់ឯកភាពលើនីតិវិធីផង ស្រាប់តែលោក.......ដែលត្រូវជាប្តីនាង.....និងបានក្រោកឈរឡើងប្រកាសប្តឹងដិតចិត្តចំពោះលោក.......មិនឱ្យជំនុំជម្រះរឿងក្តីនេះតទៅទៀត ។ ការជជែកគ្នារវាងលោក...ជាចៅក្រមទទួលការចាត់តាំងឱ្យទទួលបន្ទុកជំនុំជម្រះរឿងក្តីនេះ នឹងលោក....ក៏បានកើតមានពេលសវនាការនោះ ។ ដោយមានឧប្បត្តិហេតុកើតឡើងយ៉ាងនេះ លោកព្រះរាជអាជ្ញាចូលរួមសវនាកា បានជូនយោបល់ឱ្យលោក.......ផ្អាកសវនាការសិន ហើយបន្ទាប់មកលោកប្រធានតុលាការបានចេញសេចក្តីសម្រេចលេខ ១២៥ ចុះថ្ងៃទី២៣-០៦-៩៨ ផ្អាកសវនាការរឿងក្តីនេះទៀត ។

ក្នុងរឿងលោក....ប្តឹងដិតចិត្តនេះ លោក.....យល់ថាពុំត្រឹមត្រូវទេ ព្រោះលោក......គ្រាន់តែជាប្តីរបស់នាង.....ប៉ុណ្ណោះ ដោយឈ្មោះនេះពុំមែនជាគូក្តីក្នុងរឿងក្តីនេះឡើយ ដូច្នេះឈ្មោះនេះពុំមានគុណភាពប្តឹងដិតចិត្តចៅក្រមតាមច្បាប់ទេ។

លោក......សុំឱ្យក្រសួងជួយផ្តល់យោបល់ ដើម្បីការពារកិត្តិយសេចក្តីថ្លៃថ្នូររបស់តុលាការ និងសណ្តាប់ធ្នាប់នៃសវនាការ ។

ក្រសួងយុត្តិធម៌យល់ឃើញថា បើរឿងក្តីសុំទាមទាគ្រប់គ្រងដីធ្លីនេះ មានផលប្រយោជន៍រួមរវាងនាង....និងលោកជាសហព័ទ្ធ ដែលមានការពាក់ព័ន្ធផលប្រយោជន៍គតិយុត្តិ លោក....មានសិទ្ធិប្តឹងតវ៉ាការពារផលប្រយោជន៍រួមរបស់ខ្លួនបាន នៅក្នុងនីតិវិធីដោះស្រាយរឿងក្តី ចាប់តាំងពីតុលាការទទួលពាក្យបណ្តឹងរហូតដល់មុនពេលតុលាការប្រកាសបញ្ចប់ការសួរដេញដោលនៅពេលសវនាការ ភាគីអ្នកមានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់អាចប្តឹងសុំតវ៉ាបានគ្រប់ស្ថានភាពនៃចំណុចដែលមានផលប្រយោជន៍ស្របច្បាប់របស់ខ្លួន បណ្តឹងសុំ បណ្តឹងសុំបន្ថែម ឬបណ្តឹងតវ៉ារបស់ជនណាក៏ដោយ តុលាការត្រូវតែទទួលយកទៅដោះស្រាយ និងជំនុំជម្រះសម្រេចសេចក្តីតាមនីតិវិធីនិងតាមច្បាប់ ។

ក្នុងរឿងក្តីរដ្ឋប្បវេណី មិនថាដើមបណ្តឹងឬចុងចម្លើយ ឬជាតតិយជន ចៅក្រមត្រូវតែហៅទាំងប្តីប្រពន្ធដែលមានចំណងគតិយុត្តិ មានផលប្រយោជន៍ក្នុងរឿងក្តីនោះមកសួរលើចំណុចកម្មវត្ថុនៃបណ្តឹងដែលពាក់ព័ន្ធដល់ផល

ប្រយោជន៍រួមឬ ផលប្រយោជន៍ដោយឡែក មុននិងប្រកាសចេញសាលក្រមដល់អង្គសេចក្តីជាដរាប ។ បើចៅក្រមពុំបានធ្វើដូច្នេះទេ នីតិវិធីរបស់ចៅក្រមនោះនៅមានខ្វះចន្លោះដែលនាំឱ្យអ្នកមានសិទ្ធិ នឹងផលប្រយោជន៍ស្របច្បាប់ប្តឹងសុំចូលខ្លួនជាតតិយជន ជាដើមចោទ ឬចុងចម្លើយបាន ឬ អាចប្តឹងសុំជំទាស់ជាតតិយជន និងសាលក្រមស្តាពរួចហើយបានថែមទៀតផង ។

ឧប្បត្តិហេតុកើតឡើងក្នុងនីតិវិធីរបៀបនេះ យើងពុំទាន់មាននីតិវិធីរដ្ឋប្បវេណីជាធរមានសម្រាប់យកមកដោះស្រាយទេ តែយើងមានច្បាប់ស្តីពីនីតិវិធីជំនុំជម្រះផ្នែកព្រហ្មទណ្ឌជាធរមាន ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី១៦-០៧-៩៨ ហើយមានពាក់ពន្ធដល់មាត្រា៣២-៣៤-៣៧ ដែលទាំងចៅក្រមជំនុំជម្រះទាំងប្រធានឬអនុប្រធានតុលាការ និងប្រធានតុលាការកំពូល សម្រាប់យកមកដោះស្រាយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

<u>ចម្លងជូន</u>

-តុលាការ និងអយ្យការខេត្ត ក្រុង

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

-ដើម្បីជ្រាប និងអនុវត្ត